ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ : ០២៧៧/១៨ ក.ប/ស.ជ.ណ.វ.ប.ប

# សេចក្តីជូនដំណឹង

## ស្តីពី

## ការជ្រើសរើសមន្ត្រីរាជការ និងសិស្ស-និស្សិតឲ្យចូលបម្រើការងារ ក្នុងក្របខ័ណ្ឌក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ឆ្នាំ២០១៨

**យោង ៖** លិខិតលេខ ៤០៨៤ មស.ក្រ.ខ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់ក្រសួងមុខងារសាធារណៈ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់មន្ត្រីរាជការ សិស្ស-និស្សិត បុគ្គលិក ក្រុមហ៊ុន អង្គការ ឲ្យបានជ្រាបថា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងឆ្នាំ២០១៨ នេះត្រូវការជ្រើសរើសមន្ត្រីរាជការក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល(ក្របខ័ណ្ឌប្រភេទ "ក") ចំនួន **១៤**កន្លែង ដោយបែងចែកទៅតាមអង្គភាពដូចខាងក្រោម ៖

| ល.រ | អង្គភាពជ្រើសរើស | ចំនួន | ល.រ | អង្គភាពជ្រើសរើស | ចំនួន |
|---|---|---|---|---|---|
| ១ | ទីស្តីការក្រសួង | ៤ | ៧ | មន្ទីរ ក.ប ខេត្តត្បូងឃ្មុំ | ១ |
| ២ | មន្ទីរ ក.ប ខេត្តកែប | ១ | ៨ | មន្ទីរ ក.ប ខេត្តកំពង់ឆ្នាំង | ១ |
| ៣ | មន្ទីរ ក.ប ខេត្តកំពត | ១ | ៩ | មន្ទីរ ក.ប ខេត្តពោធិ៍សាត់ | ១ |
| ៤ | មន្ទីរ ក.ប ខេត្តព្រះសីហនុ | ១ | ១០ | មន្ទីរ ក.ប ខេត្តបាត់ដំបង | ១ |
| ៥ | មន្ទីរ ក.ប ខេត្តសៀមរាប | ១ | ១១ | មន្ទីរ ក.ប ខេត្តកំពង់ស្ពឺ | ១ |
| ៦ | មន្ទីរ ក.ប ខេត្តកំពង់ធំ | ១ | | | |
| **សរុប ១៤** (កន្លែង) | | | | | |

### ១-កម្រិតសញ្ញាបត្រ និងលក្ខខណ្ឌនៃការជ្រើសរើស

- បេក្ខជនត្រូវមានសញ្ជាតិខ្មែរ
- សញ្ញាបត្រយ៉ាងទាបបំផុតត្រឹមកម្រិតបរិញ្ញាបត្រ ឬសញ្ញាបត្រសមមូល
- បេក្ខជនដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឬសមមូល ត្រូវមានអាយុច្រើនបំផុត ៤០ឆ្នាំ
- បេក្ខជនដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រឬសមមូល ត្រូវមានអាយុច្រើនបំផុត ៣៥ឆ្នាំ
- បេក្ខជនជាមន្ត្រីរាជការ និងបេក្ខជនដែលមានកម្រិតបណ្តុះបណ្តាលចាប់ពីបណ្ឌិតឡើងទៅ ត្រូវបានលើកលែងលក្ខខណ្ឌអាយុ
- បេក្ខជនជាមន្ត្រីរាជការត្រូវមានលិខិតអនុញ្ញាតឲ្យប្រឡងពីក្រសួង ស្ថាប័ន ឬអង្គភាព និងត្រូវអនុញ្ញាតឲ្យផ្ទេរក្របខ័ណ្ឌ ឬផ្លាស់កន្លែងធ្វើការនៅពេលប្រកាសលទ្ធផលប្រឡងជាប់ជាស្ថាពរ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- បេក្ខជនជាមន្ត្រីរាជការនឹងត្រូវបានរក្សាអតីតភាពការងារ ប៉ុន្តែតួនាទី ឬមុខតំណែងមិនត្រូវបានរក្សានោះទេ
- ក្រសួងនឹងទទួលយកជនពិការចំនួន ០១រូប ដោយស្វ័យប្រវត្តិក្នុងចំណោមបេក្ខជនពិការដែលបានប្រឡង ហើយបានទទួលពិន្ទុខ្ពស់ជាងគេ
- ពេលមកដាក់ពាក្យសុំប្រឡង បេក្ខជនទាំងពីរភេទត្រូវនាំមកជាមួយនូវសញ្ញាបត្រច្បាប់ដើមដើម្បីបង្ហាញដល់មន្ត្រីទទួលខុសត្រូវ
- ផ្តល់អាទិភាពដោយបន្ថែមពិន្ទុលើមធ្យមភាគចុងក្រោយនៃពិន្ទុសរុប ១០០% ចំពោះ ៖

  ១/ បេក្ខជនជាមន្ត្រីជាប់កិច្ចសន្យា.......................................................បន្ថែម៥ពិន្ទុ

  ២/ បេក្ខជនជាស្ត្រី.......................................................................បន្ថែម២ពិន្ទុ

ការបន្ថែមនេះ ផ្តល់ជូនតែមួយប្រភេទក្នុងករណីដែលបេក្ខជនមានលក្ខណៈសម្បត្តិលើសពី១ ដោយលក្ខខណ្ឌបន្ថែមពិន្ទុច្រើនជាងក្នុងចំណោមលក្ខខណ្ឌដែលបេក្ខជនមាន ។

**២-វិញ្ញាសា និងរយៈពេលប្រឡង**

- ចំណេះដឹងទូទៅពាក់ព័ន្ធ រដ្ឋបាល និងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ.............................................................................................................រយៈពេល ២ម៉ ០០នាទី (មេគុណ៣)
- ភាសាអង់គ្លេស(QCM).......................................................រយៈពេល ១ម៉ ៣០នាទី (មេគុណ១)

❖ **<u>បញ្ជាក់៖</u>** បេក្ខជនទាំងពីរភេទ ត្រូវអនុវត្តតាមការកំណត់វិញ្ញាសាប្រឡងខាងលើ ដោយមិនអាចតវ៉ានៅពេលប្រឡង ដើម្បីឲ្យមានការកែសម្រួលតាមជំនាញរបស់ខ្លួនឡើយ ។

**៣-កាលបរិច្ឆេទលក់ពាក្យ-ទទួលពាក្យ និងឈប់ទទួលពាក្យ**

- កាលបរិច្ឆេទលក់ពាក្យ និងទទួលពាក្យចាប់ពីថ្ងៃជូនដំណឹងនេះតទៅរៀងរាល់ម៉ោងធ្វើការ ពេលព្រឹកចាប់ពីម៉ោង ០៧:៣០-១១:៣០នាទី និងពេលរសៀលចាប់ពីម៉ោង ១៤:៣០-១៧:០០នាទី ។
- កាលបរិច្ឆេទឈប់ទទួលពាក្យ នៅថ្ងៃទី**២៨ ខែកញ្ញា ឆ្នាំ២០១៨ វេលាម៉ោង១៧:០០នាទីល្ងាច**

**៤-កាលបរិច្ឆេទប្រឡង និងមណ្ឌលប្រឡង**

- មណ្ឌលប្រឡងនឹងបិទផ្សាយនៅទីស្តីការក្រសួង **នាថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨**
- កាលបរិច្ឆេទប្រឡង**ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៨**

**៥-សំណុំលិខិតចុះឈ្មោះប្រឡង**

- ពាក្យសុំចុះឈ្មោះប្រឡង ..............................................................ចំនួន ០១ច្បាប់
- សេចក្តីចម្លងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងបរិញ្ញាបត្រ ឬអនុបណ្ឌិត ឬបណ្ឌិត ឬសញ្ញាបត្រដែលមានតម្លៃសមមូលដោយមានបញ្ជាក់ពីអាជ្ញាធរដែនដី ....................ចំនួន ០១ច្បាប់
- ប្រវត្តិរូបសង្ខេបមានបិទរូបថត ៤x៦...................................................ចំនួន ០១ច្បាប់
- សលាកបត្រឯកត្តជន.......................................................................ចំនួន ០១ច្បាប់
- កិច្ចសន្យាបម្រើការងារក្រសួង..........................................................ចំនួន ០១ច្បាប់
- បង្កាន់ដៃបង់សិទ្ធិប្រឡង ...................................................................ចំនួន ០១ច្បាប់
- រូបថតថ្មី ៤x៦ ថតចំពីមុខគ្មានពាក់វ៉ែនតា ឬមួក .......................................ចំនួន០២សន្លឹក
- លិខិតថ្កោលទោស(ក្រោយពេលប្រឡងជាប់ជាស្ថាពរ) ..................................ចំនួន ០២ច្បាប់
- លិខិតពិនិត្យកាយសម្បទា(ក្រោយពេលប្រឡងជាប់ជាស្ថាពរ)..........................ចំនួន ០២ច្បាប់
- លិខិតអនុញ្ញាតឲ្យប្រឡងពីក្រសួង ស្ថាប័ន ឬអង្គភាពដែលកំពុងបម្រើការងារ ............ចំនួន ០១ច្បាប់

- ប្រកាស/ស្វ័យប្រកាសស្តីពីការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យាឆ្នាំ២០១៨ សម្រាប់បេក្ខជនជាមន្ត្រីជាប់កិច្ចសន្យារបស់ក្រសួង ឬអង្គភាពក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ .........ចំនួន០១ច្បាប់

**៦-កំណត់សំគាល់**

- បេក្ខជនត្រូវសរសេរបំពេញពាក្យសុំប្រឡងដោយដៃ ចុះហត្ថលេខា ឬផ្តិតស្នាមមេដៃ និងមកដាក់ពាក្យដោយផ្ទាល់ ព្រមទាំងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ ដូចមានចែងក្នុងចំណុច "៥" ។
- កន្លែងទំនាក់ទំនងផ្តល់ពាក្យ និងទទួលពាក្យប្រឡង ៖

  ក/ សម្រាប់ទីស្តីការក្រសួង នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ***អាសយដ្ឋាន អគារលេខ៣ មហាវិថី សហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក (ទូរស័ព្ទ ០២៣ ៨៨៤ ៣៧៥)*** ជាប់វិទ្យាស្ថានភាសាបរទេស នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។

  ខ/ គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត ដែលត្រូវជ្រើសរើស ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម មន្ត្រីរាជការ សិស្ស-និស្សិត បុគ្គលិកក្រុមហ៊ុន អង្គការ ដែលមានបំណងចង់ដាក់ពាក្យសុំប្រឡង មេត្តាជ្រាប និងអនុវត្តតាមការគួរ ។

ថ្ងៃ សុក្រ ៨ កើត ខែ ទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ក្រសួងព័ត៌មាន
- គ្រប់អង្គភាពចំណុះក្រសួង "ដើម្បីជួយផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ